ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១៦ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
# ស្តីពី
# គណនាគារគយមានដែនកំណត់

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ ស្តីពីការរៀប ចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

កំណត់នីតិវិធីនៃការបង្កើត ការផ្តល់អាជ្ញាប័ណ្ណ និងកិច្ចដំណើរការនៃគណនាគារគយមានដែនកំណត់ ដោយអនុលោមតាមបញ្ញត្តិមាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៩ នៃច្បាប់ស្តីពីគយ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

កណ្ដាគារគយមានដែនកំណត់គឺជាអាគារ ទីកន្លែង ឬទីលាន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើសន្និធិទំនិញ ក្រោមការត្រួតពិនិត្យរបស់គយសម្រាប់រយៈពេលជាក់លាក់មួយ និងដោយមានបញ្ជាក់ពីពេលវេលាច្បាស់លាស់ ។ ទំនិញនាំចូល និងទំនិញក្នុងស្រុកសម្រាប់នាំចេញ អាចត្រូវបានដាក់ក្នុងកណ្ដាគារគយមានដែនកំណត់ ។

**ប្រការ ២ .-**

ទំនិញក្នុងកណ្ដាគារគយមានដែនកំណត់ ត្រូវបានព្យួរពន្ធ និងអាករដែលត្រូវជាប់ ។ ការហាមឃាត់ ឬការដាក់កម្រិតកំណត់នានាលើទំនិញទាំងនេះ អាចត្រូវបានលើកលែងរហូតដល់ពេលដែលទំនិញត្រូវបានបញ្ចេញពីគយសម្រាប់ការប្រើប្រាស់ក្នុងប្រទេស ឬដើម្បីនាំចេញ ។

**ប្រការ ៣ .-**

កណ្ដាគារគយមានដែនកំណត់មានបីប្រភេទ ៖

- ប្រភេទ **ក** : កណ្ដាគារសាធារណៈ គឺជាកណ្ដាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលអាចធ្វើប្រតិបត្តិការដោយភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬដោយបុគ្គលណាមួយ ។ កណ្ដាគារនេះត្រូវបានប្រើប្រាស់សម្រាប់ផ្ដល់សេវាដល់បុគ្គលណាមួយ ដែលមានសិទ្ធិស្របច្បាប់លើទំនិញ ឱ្យធ្វើសន្និធិទំនិញ រាប់បញ្ចូលទាំងអ្នកនាំចូល បុគ្គលដែលទិញទំនិញក្នុងកណ្ដាគារនេះ ឬបុគ្គលណាមួយផ្សេងទៀតដែលមានសិទ្ធិស្របច្បាប់លើទំនិញទាំងនេះ។

- ប្រភេទ **ខ** : កណ្ដាគារឯកជន គឺជាកណ្ដាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីនាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវបានប្រើប្រាស់ដោយឡែកដោយបុគ្គលណាម្នាក់សម្រាប់ធ្វើសន្និធិទំនិញ ដើម្បីតែប្រើប្រាស់ដោយឡែក រាប់បញ្ចូលទាំងប្រតិបត្តិករអាគារលក់ទំនិញរួចពន្ធផង។

- ប្រភេទ **គ** : កណ្ដាគារពិសេស គឺជាកណ្ដាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីនាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់គោល[illegible]ទ

ទំនិញគ្រោះថ្នាក់ ប៉ះពាល់ដល់គុណភាពទំនិញដទៃទៀត ឬអាចត្រូវការទីកន្លែងពិសេសសម្រាប់រក្សាទំនិញទាំងនោះ ។ កណ្តាគារគយប្រភេទនេះអាចជាកណ្តាគារសាធារណៈ ឬឯកជន ។

**ប្រការ ៤ .-**

អាជ្ញាប័ណ្ណសម្រាប់កណ្តាគារគយមានដែនកំណត់ត្រូវកំណត់នូវលក្ខខណ្ឌនៃកិច្ចសន្យា និងប្រតិបត្តិការធុរកិច្ច រវាងរដ្ឋបាលគយ និងប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ ។ កិច្ចសន្យានេះត្រូវកំណត់នូវ ៖

- សិទ្ធិ ភារកិច្ច និងកាតព្វកិច្ច របស់ភាគីនីមួយ ៗ
- ទីតាំងនៃកណ្តាគារគយមានដែនកំណត់
- រយៈពេលប្រតិបត្តិការ និងលទ្ធភាពនៃការពន្យាសុពលភាព
- គម្រោងអាគារ និងផែនទីការដ្ឋាន
- ទម្រង់ និងចំនួន ទឹកប្រាក់នៃនិមុត្តិធានា
- នីតិវិធីសម្រាប់ចាត់ចែង និងគ្រប់គ្រង
- បែបបទនៃការដឹកជញ្ជូនឆ្លងកាត់
- មុខទំនិញដែលត្រូវអនុញ្ញាតឱ្យដាក់នៅក្នុងកណ្តាគារគយ
- ការតម្រូវឱ្យធ្វើប្រតិវេទន៍គយ
- លក្ខខណ្ឌផ្សេងទៀតដែលអាចតម្រូវដោយរដ្ឋបាលគយ ។

**ប្រការ ៥ .-**

បុគ្គលណាមួយមានបំណងបំពេញធុរកិច្ចជាប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ត្រូវស្នើសុំទៅនាយកទីចាត់ការគយ និងរដ្ឋាករ តាមទម្រង់កំណត់ ដោយភ្ជាប់ជាមួយនូវ គម្រោងប្លង់សំណង់លម្អិត និងទីតាំងដែលត្រូវសាងសង់កណ្តាគារនោះ ។

អាជ្ញាប័ណ្ណអាចត្រូវផ្តល់ជូនបាន ក្នុងករណីដែលលក្ខខណ្ឌដូចខាងក្រោមនេះត្រូវបានបំពេញ ៖

- អ្នកស្នើសុំត្រូវមានលិខិតបញ្ជាក់ថាគ្មានទោស ដែលចេញដោយតុលាការមានសមត្ថកិច្ច

-អ្នកស្នើសុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីផ្តល់នូវទីកន្លែង សម្ភារៈ បរិក្ខារ ឧបករណ៍ បុគ្គលិក និងសេវាកម្ម ចាំបាច់នានាសម្រាប់កិច្ចដំណើរការ កណ្ដាគារគយមានដែនកំណត់

- អ្នកស្នើសុំមានប្រវត្តិអនុលោមភាពលើកាតព្វកិច្ចសារពើពន្ធស្អាតស្អំ

- រដ្ឋបាលគយពិនិត្យឃើញថា សំណើសុំនេះមានប្រសិទ្ធិភាពសេដ្ឋកិច្ច

- ទីតាំងកណ្ដាគារគយដែលស្នើសុំ ស្ថិតនៅចម្ងាយសមស្របមួយពីផ្លូវគមនាគមន៍សំខាន់ៗ និងពីការិយាល័យគយ មានទីធ្លាសមល្មមសម្រាប់ធ្វើសន្និធិទំនិញប្រកបដោយសុវត្ថិភាព

- រដ្ឋបាលគយអាចគ្រប់គ្រង និងផ្តល់សេវាកម្មបានក្នុងកណ្ដាគារនេះ ។

អាជ្ញាប័ណ្ណអាចត្រូវបានកែសម្រួល ឬបំពេញបន្ថែមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងគោលបំណង ៖

- ផ្លាស់ប្តូរនូវការដាក់កម្រិតកំណត់ ឬលក្ខខណ្ឌនានាក្នុងអាជ្ញាប័ណ្ណពាក់ព័ន្ធនឹងទំនិញដែលអាចត្រូវបានអនុញ្ញាតឱ្យដាក់ក្នុងកណ្ដាគារ ឬដើម្បីបញ្ជាក់នូវកម្រិតកំណត់នូវលក្ខខណ្ឌទាំងនេះ

- ផ្លាស់ប្តូរនាមករណ៍អ្នកទទួលអាជ្ញាប័ណ្ណក្នុងករណីចាំបាច់ ។

អាជ្ញាប័ណ្ណអាចត្រូវបានបដិសេធដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ ៖

- លែងជាម្ចាស់កម្មសិទ្ធិ ឬជាអ្នកជួល ទិញ ទីកន្លែងដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណជាកណ្ដាគារគយមានដែនកំណត់

- ស្នើសុំជាលាយល័ក្ខអក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបដិសេធអាជ្ញាប័ណ្ណ

- ត្រូវបានក្ស័យធន ។

អាជ្ញាប័ណ្ណអាចត្រូវបានព្យួរ ឬបដិសេធ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ ៖

- ជាកម្មវត្ថុនៃការបង្ខំឱ្យសងបំណុលតាមផ្លូវតុលាការ

- មិនបានបំពេញតាមបញ្ញត្តិនៃប្រកាសនេះ

- ប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃច្បាប់ ឬបទប្បញ្ញត្តិនានាជាធរមានពាក់ព័ន្ធទៅនឹងការនាំចូល ឬការនាំចេញទំនិញ ។

- ប្រព្រឹត្តភាពមិនស្មោះត្រង់ក្នុងធុរកិច្ចរបស់ខ្លួនជាមួយដើងសារគយ អ្នកនាំចូល អ្នកនាំចេញ អ្នកដឹកជញ្ជូន ឬស្ថាប័ននានារបស់រាជរដ្ឋាភិបាល

- គ្មានសមត្ថភាពគ្រប់គ្រងកិច្ចដំណើរការកណ្តាគារគយមានដែនកំណត់

-ពុំមានទំនិញគ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពនៃកិច្ចប្រតិបត្តិការកណ្តាគារគយមានដែនកំណត់

- រដ្ឋបាលគយពុំមានលទ្ធភាពផ្តល់សេវាកម្មដល់កណ្តាគារគយមានដែនកំណត់នោះតទៅទៀត

នៅពេលដែលអាជ្ញាប័ណ្ណត្រូវបានព្យួរ កណ្តាគារគយមានដែនកំណត់នឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ ហើយរដ្ឋបាលគយ អាចចាក់សោរ និងបិទត្រាគយលើកណ្តាគារនេះសម្រាប់រយៈពេលនៃការព្យួរអាជ្ញាប័ណ្ណ ។

**ប្រការ ៦ .-**

ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ត្រូវបង់កម្រៃអាជ្ញាប័ណ្ណប្រចាំឆ្នាំស្មើនឹង មួយភាគរយ (១%) នៃប្រាក់ពន្ធ និងអាករជាមធ្យមប្រចាំខែដែលត្រូវជាប់លើទំនិញក្នុងកណ្តាគារ។ កម្រៃនេះត្រូវបង់នៅពេលដំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។ ប្រសិនបើអាជ្ញាប័ណ្ណត្រូវបានចេញក្រោយថ្ងៃទីមួយខែកក្កដា កម្រៃអាជ្ញាប័ណ្ណសម្រាប់ឆ្នាំសារពើពន្ធនោះត្រូវស្មើនឹងពាក់កណ្តាលនៃកម្រៃប្រចាំឆ្នាំ ។

**ប្រការ ៧ .-**

ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ ត្រូវតម្កល់និមុត្តិធានាជូនរដ្ឋបាលគយជាទឹកប្រាក់ស្មើនឹង ប្រាំភាគរយ (៥%) នៃទឹកប្រាក់ពន្ធ និងអាករ ប្រចាំឆ្នាំ ដែលត្រូវជាប់លើទំនិញក្នុងកណ្តាគារ ។ ទម្រង់នៃនិមុត្តិធានាត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ៤១ នៃច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

សម្រាប់ឆ្នាំទីមួយនៃប្រតិបត្តិការកណ្តាគារគយមានដែនកំណត់ នាយកទីចាត់ការគយ និងរដ្ឋាករត្រូវកំណត់ទំហំនៃទឹកប្រាក់និមុត្តិធានា ។

រដ្ឋបាលគយត្រូវផ្ទៀងផ្ទាត់ថាទំហំនៃទឹកប្រាក់និមុត្តិធានាគ្រប់គ្រាន់តាមតម្រូវការដូចមានចែងក្នុងវាក្យខណ្ឌទី មួយ ខាងលើ ហើយក្នុងករណីចាំបាច់អាចកែសម្រួលទំហំទឹកប្រាក់និមុត្តិធានានេះ ។

**ប្រការ ៨ .-**

ប្រតិបត្តិករកណ្ដាគារគយមានដែនកំណត់ ត្រូវទទួលបន្ទុកលើការចំណាយពាក់ព័ន្ធនឹងកិច្ចដំណើរការ ការថែរក្សា និងជួសជុលកណ្ដាគារ ហើយត្រូវធានាដោះស្រាយទីកន្លែងសមរម្យ គ្រប់គ្រាន់ដោយមិនយកកម្រៃជូនមន្ត្រីគយដើម្បីបំពេញការងាររបស់ខ្លួន ។

ប្រតិបត្តិករកណ្ដាគារគយមានដែនកំណត់ត្រូវផ្ដល់បុគ្គលិក និងសម្ភារៈបរិក្ខារចាំបាច់ជូនមន្ត្រីគយសម្រាប់ការត្រួតពិនិត្យទំនិញឱ្យបានត្រឹមត្រូវ និងត្រូវមានបុគ្គលិកគ្រប់គ្រាន់សម្រាប់គ្រប់គ្រងកណ្ដាគារ ថែរក្សាឯកសារ និងបញ្ជីស្នាមគណនេយ្យ និងផ្ដល់ឯកសារទាំងនោះជូនមន្ត្រីគយពេលមានតម្រូវការ ។

កណ្ដាគារគយមានដែនកំណត់ត្រូវមានសុវត្ថិភាពដោយមានការចាក់សោរទ្វារ និងបង្អួច ។ ទំនិញត្រូវតែបានសន្និធិប្រកបដោយសុវត្ថិភាព ហើយនីតិវិធីសមស្របមួយត្រូវបានដាក់ឱ្យអនុវត្តដើម្បីរក្សាសន្តិសុខ ។ ការចេញចូលកណ្ដាគារនេះត្រូវបានអនុញ្ញាតសម្រាប់តែបុគ្គលមួយចំនួន តាមការកំណត់របស់រដ្ឋបាលគយប៉ុណ្ណោះ ។

**ប្រការ ៩ .-**

ប្រតិបត្តិករកណ្ដាគារគយមានដែនកំណត់ ត្រូវថែរក្សាសំណុំឯកសារនានានៃទំនិញទាំងអស់ដែលធ្វើសន្និធិក្នុងកណ្ដាគារនេះ ដោយអនុលោមតាមការតម្រូវរដ្ឋបាលគយ និងត្រូវធានាឱ្យមានការគ្រប់គ្រង និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនៅទីកន្លែងដើម្បីបង្ការនូវការបាត់បង់ទំនិញ ។

សំណុំឯកសាររបស់ប្រតិបត្តិករ ត្រូវបង្ហាញនូវចលនាទំនិញដែលស្ថិតក្រោមការគ្រប់គ្រងរបស់គយ ក្នុងកណ្ដាគារគយមានដែនកំណត់ដែលរាប់បញ្ចូល ៖

- ចលនាទំនិញចូលក្នុងកណ្ដាគារ

- ចលនាទំនិញសន្និធិក្នុងកណ្តាគារ
- ការផ្ទេរទំនិញទៅ ឬមកពីកណ្តាគារគយមានដែនកំណត់ផ្សេងទៀត
- ការធ្វើសហត្ថកម្មផ្សេងៗ ដូចជា ការដេរប៉ះស្រោមសម្បករហែក ការរៀបចំកញ្ចប់ទំនិញឡើងវិញ ការជ្រើសរើស ឬវេចខ្ចប់ឡើងវិញជាដើម
- ការយកទំនិញចេញពីកណ្តាគារ ។

រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់ជាប្រចាំរវាងសំណុំឯកសារ និងទំនិញដាក់ស្តុកក្នុងកណ្តាគារដើម្បីឃ្លាំមើលអនុលោមភាព ។

ការខកខានរក្សាទុកឱ្យបានត្រឹមត្រូវនូវសំណុំឯកសារទាំងនេះ ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ ត្រូវទទួលរងនូវការពិន័យតាមច្បាប់ជាធរមាន ។ ក្នុងករណីដែលការមិនគោរពអនុលោមភាពនៅតែបន្ត ប្រតិបត្តិករអាចរងនូវការព្យួរ ឬលុបចោលនូវអាជ្ញាប័ណ្ណកណ្តាគារគយមានដែនកំណត់នេះ ។

**ប្រការ ១០ .-**

ទំនិញអាចរក្សាទុកក្នុងកណ្តាគារគយមានដែនកំណត់ រហូតដល់រយៈពេលពីរ (២) ឆ្នាំគិតពីថ្ងៃចុះបញ្ជីការប្រតិវេទន៍គយ ។ ប្រសិនបើទំនិញស្ថិតក្នុងសភាពល្អ រយៈពេលកំណត់នេះអាចត្រូវបានពន្យាររហូតដល់ ដប់ពីរ ( ១២ ) ខែ ដោយរដ្ឋបាលគយ តាមការស្នើសុំរបស់ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់មុនពេលផុតរយៈពេលកំណត់ ។

**ប្រការ ១១ .-**

ទំនិញដែលស្ថិតក្នុងកណ្តាគារគយមានដែនកំណត់អាចត្រូវបានលក់ ឬផ្ទេរ ។ អ្នកនាំចូល ឬម្ចាស់ទំនិញត្រូវជូនដំណឹងជាលាយលក្ខ័អក្សរដល់រដ្ឋបាលគយពីការផ្ទេរកម្មសិទ្ធិនេះ ។

ទំនិញដែលស្ថិតក្នុងកណ្តាគារគយមានដែនកំណត់អាចត្រូវបានផ្ទេរទៅកណ្តាគារគយមានដែនកំណត់មួយទៀត ក្រោមការត្រួតពិនិត្យគយ ។ សំណុំឯកសារពាក់ព័ន្ធនឹងការផ្ទេរទំនិញដូចនេះត្រូវដាក់ជូនរដ្ឋបាលគយ ។

**ប្រការ ១២ .-**

ទំនិញដែលយកចេញពីកណ្តាគារគយមានដែនកំណត់សម្រាប់នាំចេញ ត្រូវជាកម្មវត្ថុនៃការតម្កល់ប្រតិវេទន៍គយនាំចេញ ហើយពុំត្រូវជាប់ពន្ធ អាករនាំចូល ឬនាំចេញទេ លើកលែងតែទំនិញក្នុងស្រុកដែលអាចជាប់អាករនាំចេញ ។

ទំនិញដែលយកចេញពីកណ្តាគារគយមានដែនកំណត់ សម្រាប់ដាក់ឱ្យប្រើប្រាស់ក្នុងស្រុកត្រូវជាប់ពន្ធ និងអាករតាមអត្រាពន្ធ និងអាករជាធរមាននៃថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ដើម្បីយកទំនិញចេញពីកណ្តាគារ ។

**ប្រការ ១៣ .-**

ម្ចាស់ទំនិញក្នុងកណ្តាគារគយមានដែនកំណត់ អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយ ដើម្បីពិនិត្យមើលទំនិញ ដកគម្រូទំនិញ និងធ្វើប្រតិបត្តិការចាំបាច់នានា ក្នុងគោលបំណងថែរក្សាទំនិញទាំងនោះដោយមិនផ្លាស់ប្តូរលក្ខណៈសំខាន់នៃទំនិញនេះ រួមមាន ការបាញ់ថ្នាំសម្លាប់សត្វល្អិត ការសម្ងួត ការសម្អាត ការសាកល្បង ការជួសជុលស្រោមសម្បករហែក ការបិទស្លាកសម្គាល់ ការសរសេរចំណាំ ការរៀបចំកញ្ចប់ទំនិញឡើងវិញ ការជ្រើសរើសឬវេចខ្ចប់ឡើងវិញជាដើម ។

**ប្រការ ១៤ .-**

ស្ថិតក្នុងកាលៈទេសៈជាក់ស្តែង ការកែច្នៃ បំលែង និងផលិតទំនិញក្នុងកណ្តាគារគយមានដែនកំណត់ (Customs Bonded Warehouse) អាចត្រូវបានអនុញ្ញាត ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរូបភាពជា កណ្តា គារផលិតកម្មមានដែនកំណត់ស្ថិតក្រោមការគ្រប់គ្រងរបស់គយ (Customs Manufacturing Bonded Warehouse) ដោយអនុលោមតាមបញ្ញត្តិនានានៃប្រកាសនេះដែលពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ ។ ប្រតិបត្តិករនៃកណ្តាគារដូចនេះ ត្រូវបានអនុញ្ញាតឱ្យនាំចូលដោយព្យួរពន្ធ និងអាករនាំចូលនូវមុខទំនិញជាវត្ថុធាតុដើម ធាតុផ្សំ គ្រឿងម៉ាស៊ីនឧបករណ៍ និងសម្ភារៈបរិក្ខារដែលត្រូវប្រើដោយផ្ទាល់ក្នុងការផលិត ឬកែច្នៃទំនិញ ។

អាជ្ញាប័ណ្ណប្រតិបត្តិការកណ្តាគារផលិតកម្មមានដែនកំណត់ ត្រូវភ្ជាប់នូវបញ្ជីមុខទំនិញជាវត្ថុធាតុដើម ធាតុផ្សំ គ្រឿងម៉ាស៊ីន ឧបករណ៍ និងសម្ភារៈបរិក្ខារដែលអាចនឹងត្រូវនាំចូលដោយព្យួរពន្ធ និងអាករ ។

ទំនិញនាំចូលដែលត្រូវបានយកពីកណ្តាគារផលិតកម្មមានដែនកំណត់ សម្រាប់ការប្រើប្រាស់ក្នុងប្រទេសត្រូវជាប់ពន្ធ និងអាករដោយអនុលោមបញ្ញត្តិ មាត្រា ៤៩ នៃច្បាប់ស្តីពីគយ ។

ផលិតផលសម្រេចដែលយកចេញពីកណ្តាគារផលិតកម្មមានដែនកំណត់ សម្រាប់ការប្រើប្រាស់ក្នុងប្រទេសត្រូវជាប់ពន្ធ និងអាករ លើតម្លៃវត្ថុធាតុដើម ឬធាតុផ្សំដែលបាននាំចូលដោយព្យួរពន្ធ និងអាករ ហើយបានប្រើប្រាស់ក្នុងការផលិត ។

ពន្ធ និងអាករទាំងនេះ ត្រូវប្រមូលផ្អែកតាមតារាងពន្ធគយ ហើយអត្រាពន្ធ និងអាករដែលត្រូវប្រមូល គឺជាអត្រានៅក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនៅពេលដែលទំនិញទទួលបានការអនុញ្ញាតឱ្យយកចូលកណ្តាគារនេះ ។

**ប្រការ ១៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចេញអាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការកែច្នៃ ឬចំរាញ់គេលសិលាខៅ ឬប៊ីទីមខនិជ ដើម្បីទទួលបានផលិតផលគេលសិលា ត្រូវដាក់ឱ្យស្ថិតក្រោមរបបកណ្តាគារផលិតកម្មមានដែនកំណត់ក្រោមការគ្រប់គ្រងរបស់គយ ដោយអនុលោមតាមបញ្ញត្តិនានានៃប្រកាសនេះដែលពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ ។

អាជ្ញាប័ណ្ណដូចនេះត្រូវកំណត់នូវអាណត្តិ និងលក្ខខណ្ឌសម្រាប់ការធ្វើប្រតិបត្តិការកណ្តាគារផលិតកម្មមានដែនកំណត់ក្រោមការគ្រប់គ្រងរបស់គយ ។

ការព្យួរពន្ធ និងអាករអាចត្រូវបានផ្តល់ឱ្យសម្រាប់ការនាំចូលគេលសិលាខៅ ឬប៊ីទីមខនិជសម្រាប់កែច្នៃដើម្បីនាំចេញ ដោយអនុលោមតាមបញ្ញត្តិកថាខណ្ឌទី ២ មាត្រា ៤៩ នៃច្បាប់ស្តីពីគយ ។

**ប្រការ ១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៧ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់ចែងអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១៧
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ